# គាថារបស់ព្រះនាងសុមេធាថេរី

## បិដកលេខ ៥៧ ទំព័រ ២២៦

នាងសុមេធា ជាធីតានៃអគ្គមហេសីរបស់ព្រះរាជា ទ្រង់ព្រះនាមកោញ្ចៈ ក្នុងនគរឈ្មោះមន្តាវតី ជាស្ត្រីដែលព្រះអរិយៈអ្នកធ្វើតាមសាសនា បានញុំាងនាងឲ្យជ្រះថ្លាហើយ ។ នាងសុមេធា ជាស្រីមានសីល ជាធម្មកថិកាដ៏វិចិត្រ ជាពហុស្សូតជាស្រីបានបទក្នុងព្រះពុទ្ធសាសនា ចូលទៅជិតព្រះមាតាព្រះបិតាហើយទូលថា សូមទ្រង់ទាំងពីរស្តាប់ (ពាក្យខ្ញុំម្ចាស់) ។

និព្វានាភិរតា អហំ អសស្សតំ ភវគតំ យទិបិ ទិព្វំ
កិមង្គ បន តុច្ឆា កាមា អប្បស្សាទា ពហុវិឃាតា ។

ខ្ញុំម្ចាស់ជាអ្នកត្រេកអរ ចំពោះព្រះនិព្វានភពសូម្បីជាទិព្វក៏ជារបស់មិនទៀងទាត់ នឹងចាំបាច់ពោលទៅថ្វីដល់កាមទាំងឡាយដែលជារបស់សោះសូន្យ មានការត្រេកអរតិច មានសេចក្តីចង្អៀតចង្អល់ច្រើន ។

កាមា កដុកា អាសីវិសូបមា យេសុ មុច្ឆិតា ពាលា
តេ ទីឃរត្តំ និរយេ សមប្បិតា ហញ្ញន្តេ ទុក្ខិតា។

ពួកជនពាល ឈ្លក់ក្នុងកាមទាំងឡាយណា កាមទាំងឡាយនោះ ជាសភាវៈខ្លោចផ្សា ឧបមាដូចជាអាសិរិស ពួកជនពាលទាំងនោះ សឹងពេញណែនតៀបត្រាក្នុងនរក រងទុក្ខលំបាកអស់កាលដ៏អង្វែង ។

សោចន្តិ បាបកកម្មា វិនិបាតេ បាបពុទ្ធិនោ

សទា កាយេន វាចាយ ច មនសា ច អសំវុតា ពាលា ។

ពួកជនពាល មានកម្មដ៏លាមក មានគំនិតអាក្រក់មិនសង្រួម កាយ វាចា ចិត្ត រមែងសង្រេងសង្រៃ ក្នុងវិនិបាត( អបាយ) សព្វៗ កាល ។

ពាលា តេ ទុប្បញ្ញា អចេតនា ទុក្ខសមុទយោ រុទ្ធា

ទេសេន្តេ អជានន្តា ន ពុជ្ឈរេ អរិយសច្ចានិ ។

ជនពាលទាំងនោះ ឥតប្រាជ្ញាឥត ចេតនា (គឺស្លាប់គំនិត) ត្រូវតណ្ហា ជាហេតុនៃទុក្ខរួបរឹត កាលមិនដឹងនូវធម៌ ដែលព្រះសម្ពុទ្ធ ទ្រង់សម្តែង រមែងមិនត្រាស់ដឹងនូវអរិយសច្ច ទាំងឡាយ ។

សច្ចានិ អម្ម ពុទ្ធវរទេសសិតានិ តេ ពហុតរា អជានន្តា
យេ អភិនន្ទន្តិ ភវគតំ     បិហន្តិ ទេវេសុ ឧបបត្តី ។

បពិត្រព្រះមាតា ជនទាំងឡាយ ជាច្រើននាក់ណាស់ ដែលមិនដឹងនូវសច្ចធម៌ ដ៏ជាធម៌គឺព្រះពុទ្ធដ៏ប្រសើរទ្រង់សម្តែង ហើយត្រេកអរតែងនឹងភព ពេញចិត្តតែនឹងការកើតក្នុងពួកទេវតា ។

ទេវេសុបិ ឧបបត្តិ   អសស្សតា ភវគតេ អនិច្ចម្ហិ
ន ច ឧត្តសន្តិ ពាលា     បុនប្បុនំ ជាយិតព្វស្ស ។

សូម្បីការកើតក្នុងពួកទេវតាក៏មិនទៀង កាលបើភពមិនទៀង ពួកជនពាល ក៏នៅតែមិនតក់ស្លុតនឹងភព ដែលសត្វត្រូវកើតញយៗ ។

ចត្តារោ វិនិបាតា   ទ្វេ ច គតិយោ កថញ្ចិ លព្ភន្តិ
ន ច វិនិបាតគតានំ       បព្វជ្ជា អត្ថិ និរយេសុ ។

វិនិបាត ៤ (សត្វទាំងឡាយបានដោយងាយ) ឯគតិ ២ (គឺមនុស្ស និងទេវតា) បុគ្គលគប្បីបានដោយងាយដូចម្តេចកើតបព្វជ្ជារបស់ពួកសត្វវិនិបាតក្នុងនរកមិនមានឡើយ ។

អនុជានាថ មំ ឧភយោ   បព្វជិតុំ ទសពលស្ស បាវចនេ

អប្បោស្សុក្កា យជិស្សំ    ជាតិមរណប្បហានាយ ។

សូមទ្រង់ទាំងពីរអនុញ្ញាតឲ្យខ្ញុំម្ចាស់ ទៅបួសក្នុងសាសនានៃព្រះទសពល ខ្ញុំម្ចាស់នឹងជាស្រ្តីមានសេចក្តីខ្វល់ខ្វាយតិច ប្រឹងប្រែងដើម្បីលះបង់នូវជាតិនិងមរណៈ ។

កឹ ភវគតេន អភិនន្ទិតេន កាយកលិនា អសារេន

ភវតណ្ហានិរោធាយ      អនុជានាថ បព្វជិស្សាមិ ។

ប្រយោជន៍អ្វី ដោយភព ដែលអ្នកផងតែងត្រេកត្រអាលប្រយោជន៍អ្វីដោយកាយជាទោសដ៏ឥតខ្លឹមសារ សូមទ្រង់អនុញ្ញាតខ្ញុំម្ចាស់នឹងបួសដើម្បីរំលត់នូវភវតណ្ហា ។

ពុទ្ធានំ ឧប្បាទោ វិវជ្ជិតោ អក្ខណោ ខណោ លទ្ធោ

សីលានិ ព្រហ្មចរិយំ    យាវជីវំ ន ទូសេយ្យំ ។

ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ (ខ្ញុំម្ចាស់បានជួបប្រទះហើយ) កាលមិនមែនជាខណៈខ្ញុំម្ចាស់វៀរស្រឡះហើយ ខណៈខ្ញុំម្ចាស់បានហើយ ខ្ញុំម្ចាស់មិនប្រទូស្ត នូវសីល និងព្រហ្មចរិយៈរហូត អស់ជីវិត ។

នាងសុមេធា ក្រាបទូលព្រះមាតាបិតាយ៉ាងនេះថា ខ្ញុំម្ចាស់នៅជាគ្រហស្ថនឹងមិនសោយអាហារ ខ្ញុំម្ចាស់សុខចិត្តស្លាប់ ។

មាតាជាទុក្ខស្រែកយំ បិតាក៏ជាទុក្ខ ត្រូវសេចក្ដីសោកស្ដាយគ្របសង្កត់ដូចគ្នា ប្រឹងប្រែងសង្រួបសង្រួមធីតានោះ ដែលដួលចុះលើផែនដី នាផ្ទៃប្រាសាទថា:

ម្នាលកូនស្រី ចូរនាងក្រោកឡើង ប្រយោជន៍អ្វីដោយការសោក (ដើម្បីចង់បួស) យើងបានថ្វាយនាងដល់ស្ដេច ទ្រង់ព្រះនាមអនិករត្ត: ជាស្ដេចមានរូបល្អ ក្នុងនគរឈ្មោះវារណវតីហើយ ។ នាងនឹងបានជាអគ្គមហេសី នឹងបានជាភរិយារបស់ស្ដេចអនិករត្ត:នៃកូនស្រី សីល ព្រហ្មចរិយធម៌ និងបព្វជ្ជា គេធ្វើបានដោយកម្រណាស់ ។ អាណាចក្រក្នុងរាជ្យ (នៃស្ដេចអនិករត្ត:) ទ្រព្យនិងឥស្សរិយយស (ក៏មានច្រើន) ភោគសម្បត្តិទាំងឡាយនាំមកនូវសេចក្ដីសុខ (ក៏មានច្រើន) ភោគ

សម្បត្តិទាំងឡាយនាំមកនូវសេចក្តីសុខ ទាំងខ្លួននាងក៏នៅក្រមុំ ព្រោះហេតុនោះ នាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ ម្នាលកូនស្រី កិច្ចដែលគេត្រូវដណ្តឹង ចូរមានដល់នាង ។

អថ នេ ភណតិ សុមេធា មា ឯទិសកានិ ភវគតំ អសារំ

បព្វជ្ជា វា ហោតុ មរណំ វា តេនចេវ វារេយ្យំ ។

គ្រានោះ ព្រះនាងសុមេធា ក្រាបទូលមាតាបិតានោះថាសម្បត្តិទាំងឡាយប្រាកដដូច្នេះ ចូរកុំមាន (ដល់ខ្ញុំម្ចាស់) ភពជារបស់គ្មានខ្លឹមសារ បព្វជ្ជា ឬមរណៈ ចូរមានដល់ខ្ញុំម្ចាស់ ព្រោះហេតុនោះកិច្ចដែលគេត្រូវដណ្តឹង (ចូរកុំមានដល់ខ្ញុំម្ចាស់ឡើយ) ។

កិមិវ បូតិកាយំ អសុចីំ សវនគន្ធំ ភយានកំ

កុណបំ អភិសំវិសេយ្យំ គត្តំ សកិបគ្ឃរិតំ អសុចិបុណ្ណំ ។

(សរីរៈនេះ) ដូចជាដង្កូវ ជាកាយស្អុយ មិនស្អាត មានក្លិនផ្សាយទៅ គួរឲ្យខ្លាច ដូចជាការុងជារិការនៃស្បែក ពេញដោយសាកសព ពេញដោយរបស់មិនស្អាត ដែលហូតចេញក្នុងកាលម្តងៗ ។

កិមិវ តាហំ ជានន្តី វិកូលកំ មំសលោហិតុបសិត្តំ
កិមិកុលាលយំ សកុណភត្តំ កឡេវរំ កិស្សទិស្សតីតិ ។

ខ្ញុំម្ចាស់ដឹងនូវសរីរៈនោះថា ដូចជាអ្វីមួយ ដែលបូកលាបដោយសាច់និងឈាម ជារបស់គួរខ្ពើមក្រែពេក ជាលំនៅនៃហ្វូងដង្កូវ ជាចំណីនៃសត្វស្លាប ជាសាកសព (គេ) នឹងឲ្យដល់អ្នកណា ម្តេចបាន ។

និព្ពុយ្ហតិ សុសានំ អចិរំ កាយោ អបេតវិញ្ញាណោ
ឆឌ្ឌិតោ កលិង្គរំ វិយ ជិគុច្ឆមានេហិ ញាតីហិ ។

កាយដែលមានវិញ្ញាណ ប្រាសចេញហើយ មិនយូរប៉ុន្មានគេតែងដុតក្នុងព្រៃស្មសាន ពួកញាតិ ដែលខ្ពើមរអើម ក៏បោះបង់ចោលដូចជាអង្កត់អុស ។

ឆឌ្ឌូន នំ សុសានេ បរភត្តំ ន្ហាយន្តិ ជិគុច្ឆន្តា
និយកា មាតាបិតរោ កឹ បន សាធារណា ជនតា។

មាតាបិតារបស់ខ្លួន ចោលសាកសពនោះ ឲ្យជាចំណីសត្វដទៃក្នុងព្រៃស្មាសាន ខ្ពើមរអើម ងូតលាង (ខ្លួណដើរចេញទៅ) ចំណាង់បើសាធារណជន (នឹងមិនខ្ពើម) ដូចម្ដេចកើត ។

អជ្ឈោសិតា អសារេ កឡេវរេ អដ្ឋិន្ហារុសង្ឃាតេ

ខេឡស្សុមុច្ចាទនសាវ បរិបុណ្ណេ បូតិកាយម្ហិ ។

សត្វទាំងឡាយតែងជ្រុលជ្រប់ក្នុងគ្រោងកាយ ជាសាកសពឥតខ្លឹមសារ ដែលសង្ខារផ្សំផ្គុំ ដោយឆ្អឹងនិងសរសៃ ជាកាយស្អុយពេញដោយទឹកមាត់ទឹកភ្នែក ទឹកសម្បោរ និង ទឹករងៃ ។

យោ នំ វិនិព្ពុជិត្វា អព្ភន្តរមស្ស ពាហិរំ

កយិរា គន្ធស្ស អសហមានា សកាបិ មាតា ជិគុច្ឆេយ្យ ។

បើបុគ្គលពន្លាត់រាងកាយនោះ ធ្វើអាការខាងក្នុងនៃវាឲ្យត្រឡប់មកខាងក្រៅវិញ សូម្បីមាតារបស់ខ្លួនក៏ខ្ពើមរអើមអត់ទ្រាំនឹងក្លិនពុំបាន ។

ខន្ធធាតុអាយតនំ សង្ខតំ ជាតិមូលកំ

ទុក្ខំ យោនិសោ អរុចឹ ភណន្តី វារយ្យំ កិស្ស ឥច្ចេយ្យំ ។

ខ្ញុំម្ចាស់និយាយដោយឧបាយនៃប្រាជ្ញានូវខន្ធ ធាតុ អាយតនៈ ដែលសង្ខារតាក់តែង ថាមានជាតិជាឫសគល់ នាំមកនូវទុក្ខ មិនជាទីពេញចិត្ត នឹងប្រាថ្នា នូវកិច្ចដែលគេត្រូវដណ្ដឹង ដើម្បីអ្វី ។

ទិវសេ ទិវសេ តិសត្តិសតានិ នវនវា បាតេយ្យុំ កាយម្ហិ

វស្សសតម្បិ បឃាតោ សេយ្យោ ទុក្ខស្ស ចេវ ខយោ ។

លំពែង ៣ រយ ដែលសំលៀងថ្មីៗ គប្បីធ្លាក់ចុះលើកាយរាល់ៗ ថ្ងៃ ប្រសិនបើ ការអស់ទៅនៃទុក្ខ សូម្បីមានការលំបាក(យ៉ាងនេះ) អស់រយឆ្នាំ ជាការប្រសើរ ។

អជ្ឈុកគច្ឆេ ឃាតម យោ វិញ្ញូ ឯវំ សត្ថុនោ វចនំ

ទីឃោ ច តេសំ សំសារោ បុនប្បុនំ ហញ្ញមានានំ ។

បុគ្គលណា ដឹងព្រះពុទ្ធដីការរបស់ព្រះសាស្ដា យ៉ាងនេះហើយបានទទួលនូវសេចក្ដីលំបាក (ការអស់នៃទុក្ខតែងមានដល់បុគ្គលនោះ ) សង្សារ (ការអន្ទោលទៅ) របស់បុគ្គលពាលទាំងឡាយដែលលំបាករឿយៗ ជាសង្សារវែងឆ្ងាយ ។

ទេវេសុ មនុស្សេសុ ច តិរច្ឆានយោនិយា អសុរកាយេសុ

បេតេសុ ច និរយេសុ ច អបរិមិតា ទិស្សន្តេ យាតា ។

ការលំបាកតានតឹងមិនមានប្រមាណ រមែងប្រាកដក្នុងពួកទេវតា ពួកមនុស្សក្នុងកំណើតតិរច្ឆាន ក្នុងពួកអសុរកាយ ក្នុងពួកប្រេតនិងក្នុងពួកនរក ។

និរយេសុ ពហូ វិនិបាត គតស្ស កិលិស្សមានស្ស

ទេវេសុបិ អត្តាណំ និព្វានសុខា បរំ នត្ថិ ។

ក្នុងនរកមានសេចក្តីលំបាកច្រើន សត្វដែលកើតក្នុងវិនិបាតក៏លំបាក សូម្បីក្នុងទេវតា ក៏មិនមានទីពឹង សេចក្តីសុខដទៃក្រៃលែងជាងសេចក្តីសុខក្នុងព្រះនិព្វានមិនមានទេ ។

បត្តា តេ និព្វានំ យេ យុត្តា ទសពលស្ស បាវចនេ

អប្បោស្សុក្កា ឃដេន្តិ ជាតិមរណប្បហានាយ ។

បុគ្គលពួកណា ខំប្រឹងប្រែងក្នុងសាសនារបស់ព្រះទសពលជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ខំព្យាយាមលះបង់ជាតិនិងមរណៈបុគ្គលពួកនោះក៏បានដល់នូវព្រះនិព្វាន ។

អជ្ជេវ តាត អភិនក្ខមិស្សំ ភោគេហិ កឹ អសារេហិ

និព្វិណ្ណា មេ កាមា វន្តសមា តាលវត្ថុកតា ។

បពិត្រព្រះបិតា ខ្ញុំម្ចាស់នឹងចេញបួសក្នុងថ្ងៃនេះប្រយោជន៍អ្វីដោយភោគៈទាំងឡាយ ដែលជាឥតខ្លឹមសារ កាមទាំងឡាយទុកស្មើនឹងវត្ថុដែលគេខ្ជាក់ចោល ខ្ញុំម្ចាស់នឿយណាយហើយ ធ្វើឲ្យដូចដើមត្នោត ដែលដាច់ក មានតែទីតាំង(មិនអាចដុះតទៅទៀតបាន) ។

ព្រះនាងសុមេធានោះ កំពុងតែនិយាយនឹងបិតាយ៉ាងនេះស្រាប់តែព្រះបាទអនិករត្តៈ ដែលបិតាបានថ្វាយនាងឲ្យដល់ទ្រង់ស្តេចព្រះរាជដំណើរចូលទៅដល់ ដោយមានពួកកំលោះហែហាម(ព្រោះ) ការត្រូវដណ្តឹងមានក្នុងកាលប្រាកដ ហើយ ។ ក្នុងកាលនោះ នាងសុមេធា កាត់នូវសក់ទាំងឡាយ ដែលមានពណ៌ខ្មៅរលើបស្លូតទន់ ដោយព្រះខាន់ ហើយបិទទ្វារប្រាសាទ រួចចូលបឋមជ្ឈាន ។ នាងសុមេធាកំពុងតែចូលសមាបត្តិ ចម្រើននូវអនិច្ចសញ្ញា លើប្រាសាទ គាប់ជួនស្តេចអនិករត្តៈក៏យាងមកដល់នគរ ។

នាងសុមេធានោះ កំពុងតែធ្វើទុកក្នុងចិត្ត (នូវអនិច្ចសញ្ញា) ស្តេចអនិករត្តៈ ដែលស្អិតស្អាងព្រះអង្គ ដោយគ្រឿងអលង្ការជាវិការៈកែវមណីនិងមាស ក៏ឡើងមកដោយរួសរាន់ ហើយធ្វើអញ្ជលីអង្វរនាងសុមេធាថា ។ អាជ្ញាក្នុងរាជ្យរបស់យើង ទ្រព្យនិងឥស្សរិយយស (ក៏មានច្រើន) ភោគសម្បត្តិទាំងឡាយ នាំមកនូវសេចក្តីសុខ ទាំងខ្លួននាងសោត ក៏នៅក្រមុំ នាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ (ព្រោះថា) កាមសុខក្នុងលោក គេរកបានដោយកម្រណាស់ ។ រាជសម្បត្តិ យើងប្រគល់ផ្តាច់ឲ្យនាងនាងចូរប្រើប្រាស់នូវភោគសម្បត្តិទាំងឡាយ ចូរឲ្យនូវទានចុះ នាងកុំតូចចិត្តឡើយ មាតាបិតារបស់នាងជាទុក្ខ ។

តន្តំ ភណតិ សុមេធា កាមេហិ អនត្ថិកា វិគតមោហា

មា កាមេ អភិនន្ទិ កាមេស្វាទីនវម បស្ស ។

នាងសុមេធា ជាស្ត្រីមិនត្រូវការដោយកាម មានមោហៈទៅប្រាសហើយ ក៏ទូលតបស្តេចអនិករត្តៈនោះថា ព្រះអង្គកុំត្រេកត្រអាល ចំពោះកាមទាំងឡាយ ព្រះអង្គចូរឃើញទោសក្នុងកាមទាំងឡាយវិញ ។

ចាតុទ្ទីបោ រាជា មន្ធាតា អាសិ កាមភោគិនំ អគ្គោ

អតិត្តោ កាលកតោ ន ចស្ស បរិបូរិតា ឥច្ឆា ។

ព្រះរាជាទ្រង់ទីវង្គតទៅ សេចក្តីប្រាថ្នារបស់ស្តេចនោះនៅតែមិនពេញគ្រប់គ្រាន់នៅឡើយ ។

សត្ត រតនានិ វស្សេយ្យ វុដ្ឋិមា ទសទិសា សមន្តេន
ន ចត្តិ តិត្តិ កាមានំអតិត្តាវ មរន្តិ នរា ។

ភ្លៀងគប្បីបង្អុរចុះនូវរតនៈទាំងឡាយ ៧ ប្រការ ជុំវិញគ្រប់ទិសទាំង១០ សេចក្តីឆ្អែតចំពោះកាមទាំងឡាយក៏នៅតែមិនល្មមពួកនរជន រមែងស្លាប់ទៅទាំងមិនឆ្អែត ។

អសិសូលូបមា កាមា កាមា សប្បសិរោបមា
ឧក្កោបមា អនុទហន្តិ អង្គិកង្គាលសន្និភា ។

កាមទាំងឡាយប្រៀបដូចដាវនិងឈើស្រួច កាមទាំងឡាយ ប្រៀបដូចក្បាលនៃពស់ ឬ ប្រៀបដូចជាគប់ភ្លើង គ្រៀមគ្រោះដូចជារាងឆ្អឹង តែងដុតកម្តៅរឿយៗ ។

អនិច្ចា អទ្ធុវា កាមា ពហុទុក្ខា មហាវិសា

អយោគុឡោវ សន្តត្តោ  អយមូលា ទុក្ខប្ផលា ។

កាមទាំងឡាយ មិនទៀងទាត់ មិនឋិតថេរ មានទុក្ខច្រើនមានពិសខ្លាំង មានសេចក្ដីតានតឹងជាឫគល់ មានសេចក្ដីទុក្ខជាផល ដូចជាដុំ ដែកដែលកំពុងឆេះ ។

រុក្ខប្ផលូបមា កាមា មំសបេសូបមា ទុខា
សុបិនោបមា វញ្ចនីយា  កាមា យាចិតកូបមា ។

កាមទាំងឡាយ ប្រៀបដូចជាផ្លែឈើ ឬប្រៀបដូចដុំសាច់នាំមកនូវទុក្ខ កាមទាំងឡាយដូចការយល់សប្ដិ ជាគ្រឿងបញ្ឆោតដូចជារបស់ខ្ចីគេ ។

សត្តិសូលូបមា កាមា  រោគោ គណ្ឌោ អឃម និឃំ
អង្គារកាសុសទិសា  អឃមូលំ ភយំ វធោ ។

កាមទាំងឡាយដូចជាលំពែងនិងដែកស្រួច ដូចជារោគឬដូចជាបូស ជាគ្រឿងតានតឹង ចង្អៀតចង្អល់ កាមទាំងឡាយប្រាកដស្មើដោយរណ្ដៅនៃរងើកភ្លើង មានសេចក្ដីតានតឹងជាឫសជាភ័យ ជាខ្មាំង ។

ឯវំ ពហុទុក្ខា កាមា អក្ខាតា អន្តរាយិកា
គច្ឆថ ន មេ ភវគតេ វិស្សាសោ អត្ថិ អត្តនោ ។

កាមទាំងឡាយ មានសេចក្តីទុក្ខ ច្រើនយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថាជាសភាវៈធ្វើនូវសេចក្តីអន្តរាយ សូមព្រះអង្គយាងទៅវិញចុះ សេចក្តីស្និទ្ធស្នាលក្នុងភពរបស់ខ្ញុំម្ចាស់មិនមានទេ ។

កី មម បរោ ករិស្សតិ អត្តនោ សីសម្ហិ ឌយ្ហមានម្ហិ
អនុពន្ធេ ជរាមរណោ តស្ស ឃាតាយ ឃដិតព្វំ ។

បុគ្គលដទៃនឹងធ្វើនូវប្រយោជន៍ដូចម្តេច ដល់ខ្ញុំម្ចាស់កើតកាលបើក្បាលរបស់ខ្លួនត្រូវភ្លើងឆេះ កាលបើជរាមរណៈកំពុងជាប់តាម ខ្ញុំម្ចាស់ត្រូវប្រឹងប្រែង ដើម្បីកម្ចាត់បង់នូវជរាមរណៈនោះ ។

ព្រះនាងសុមេធា លុះឃើញមាតាបិតា និងស្តេចអនិករត្តៈដែលមកមិនទាន់ដល់ទ្វារ កំពុងគង់យំលើផែនដី ក៏ទូលនូវពាក្យនេះថាៈ

ទីឃោ ពាលាន សំសារោ បុនប្បុនញ្ច រោទតំ

អនមតគ្គេ បិតុ មរណោ ភាតុ វធេ អត្តនោ ច វធេ ។

សង្សារបស់បុគ្គលអន្ធពាល ដែលយំទ្ងញញយៗ ចំពោះសេចក្តីស្លាប់ របស់បិតា សេចក្តីស្លាប់របស់បងប្អូន និងសេចក្តីស្លាប់របស់ខ្លួន ក្នុងសង្សារវដ្តដែលគេមិនអាចដឹងទីបំផុតបាន ជា សង្សារវែងឆ្ងាយ ។

អស្សុ ថញ្ញំ រុធិរំ សំសារំ អនមតគ្គតោ សរថ

សត្តានំ សំសរិតំ សរាហិ អដ្ឋីនញ្ច សន្និចយំ ។

សូមទ្រង់ទាំងឡាយរលឹកនូវទឹកភ្នែក ទឹកដោះ និងឈាមកាលទ្រង់អន្ទោលទៅព្រោះសង្សារដែលគេមិនអាចដឹងទីបំផុតបាន សូមទ្រង់រលឹកនូវគំនរឆ្អឹងទាំងឡាយ របស់ពួកសត្វដែលអន្ទោលទៅមក ៗ ។

សរ ចតុរោទធី ឧបនីតេ អស្សុថញ្ញរុធិរម្ហិ

សរ ឯកកប្បមដ្ឋីនំ សញ្ចយំ វិបុលេន សមំ ។

សូមទ្រង់រលឹកដល់ទឹកភ្នែក ទឹកដោះ និងឈាម ដែលប្រៀបធៀបនឹងសមុទ្រធំទាំង ៤ សូមទ្រង់រលឹកនូវគំនរ នៃឆ្អឹងទាំងឡាយក្នុងកប្បមួយៗ ដែលនឹងភ្នំ វេបុល្លៈ។

អនមតគ្គេ សំសរតោ មហី ជម្ពុទីបមុបនីតំ
កោលដ្ឋិមត្តគុឡិកា មាតាបិតូស្វេវ នប្បហោន្តិ ។

ដុំដីប៉ុនគ្រាប់ក្រពៅ ដែលបុគ្គលលញ់ដីអស់ទាំងជម្ពូទ្វីបក៏មិនល្មម គឺតិចជាងមាតាបិតា ទាំងឡាយរបស់សត្វ កាលអន្ទោលទៅក្នុងសង្សារ ដែលគេមិនដឹងទីបំផុតបាន ។

សរ តិណកដ្ឋសាខមលាសំ ឧបនីតំ អនមតគ្គតោ
បិតូសុ ចតុរង្គុលិកា ខដិកា បិតុបិតូស្វេវ នប្បហោន្តិ ។

សូមទ្រង់រលឹកនូវស្មៅ កំណាត់ឈើ មែកឈើនិងស្លឹក ឈើដែលគេនាំមកប្រៀបធៀប គឺខ្នាច់ទាំងឡាយ (របស់ស្មៅជាដើមនោះ ) ប្រមាណបួនធ្នាប់ៗ ក៏មិនល្មមស្មើនឹងបិតា និងជីតាទាំងឡាយដែរ ព្រោះសង្សារមានទីបំផុតគេមិនអាចដឹងបាន ។

សរ កាណកច្ឆបំ បុព្វេ  សមុទ្ទេ អបរតោ ច យុគច្ឆិទ្ទំ

សិរំ តស្ស ច បដិមុក្កំ  មនុស្សលាភម្ហិ ឱបម្មំ ។

សូមទ្រង់នឹងមើលនូវអណ្តើកខ្វាក់ និងប្រហោងនឹម (ដែលខ្យល់បក់បង្វិល ) ទៅក្នុងសមុទ្រ អំពីត្រើយខាងកើតទៅទៅត្រើយដទៃទៀត និង ក្បាលអណ្តើកនោះដែលចូលទៅ (ក្នុងប្រហោងនឹម) នេះជាសេចក្តីឧបមាក្នុងការបានអត្តភាពជាមនុស្ស ។

សរ រូបំ ផេណបិណ្ឌោបមស្ស កាយកលិនោ អសារស្ស

ខន្ធេ បស្ស អនិច្ចេ សារហិ និរយេ ពហុវិឃាតេ ។

សូមទ្រង់រលឹកនូវរូបកាយជាទោស ឥតខ្លឹមសារ មានឧបមាដូចដុំនៃពពុះទឹក សូមទ្រង់ឃើញនូវខន្ធទាំងឡាយ ថាជាសភាវៈមិនទៀងទាត់សូមទ្រង់រលឹកនូវនរកទាំងឡាយ ដែលមានសេចក្តីទុក្ខក្តួលក្តៅជាច្រើន ។

សរ កដសី វឌ្ឍន្តេ បុនប្បុនំ តាសុ តាសុ ជាតីសុ

សរ កុម្ភិលភយានិ ច  សរាហិ ចត្តារិ សច្ចានិ ។

សូមទ្រង់រលឹកនូវសត្វទាំងឡាយ ដែលញ៉ាំងទីស្មសាន ឲ្យចម្រើនរឿយ ៗ ក្នុងជាតិទាំងឡាយនោះ ៗ សូមរលឹកនូវភ័យ ក្នុងការចិញ្ចឹមពោះផង សូមរលឹកនូវអរិយសច្ច ទាំង៤ ផង ។

អមតម្ហិ វិជ្ជមានេ   កឹ តវ បញ្ចកសុកេន បីតេន

សញ្ញ ហិ កាមរតិយោ    កដុកតរា បញ្ចកដុកេន ។

កាលបើអមតធម៌មាន ប្រយោជន៍អ្វី ដោយហេតុក្ដៅផ្សា៥ យ៉ាង ដែលទ្រង់សោយហើយ ដ្បិតតម្រេកក្នុងកាមទាំងអស់ក្ដៅផ្សាក្រៃពេក ព្រោះហេតុក្ដៅផ្សា៥ យ៉ាង ។

អមតម្ហិ វិជ្ជមានេ

កឹ តវកាមេហិ យេបរិឡាហោ

សញ្ញា ហិ កាមរតិយោ

ជលិតា ច កុថិតា កុបិតា សន្តាបិតា ។

កាលបើអមតធម៌ មានទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយ ដែលជារបស់ក្តៅ ក្រហាយ ដ្បិតតម្រេកក្នុងកាមទាំងអស់ (ត្រូវភ្លើង ១១កង) ឆេះពុះឡើងញាប់ញ័រ ក្តៅសព្វ ។

អសបត្តម្ហិ សមានេ

កឹ តវ កាមេហិ យេ ពហុសបត្តា

សាធារណា កាមា ពហុសបត្តា ។

កាលបើធម៌ដែលឥតសត្រូវ (នេក្ខម្ម:) មានទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយដែលមានសត្រូវច្រើន កាមទាំងឡាយជាសាធារណ: មានសត្រូវច្រើន គឺសត្រូវអំពីស្តេចភ្លើង ចោរ ទឹក និងបុគ្គលមិនជាទីស្រឡាញ់ ។

មោក្ខម្ហិ វិជ្ជមានេ កឹ តវ កាមេហិ យសុ វធពន្ធោ

កាមេសុ ហិ វធពន្ធោ កាមកាមា ទុក្ខានិ អនុភោន្តិ ។

កាលបើព្រះនិព្វាន មាន ទ្រង់មានប្រយោជន៍ អ្វី ដោយកាមទាំងលាយ ដែលជាគ្រឿងសម្លាប់ ជាគ្រឿងចង ព្រោះថាកាមទាំងឡាយ តែងមានគ្រឿងសម្លាប់និង

គ្រឿងចង ពួកសត្វនេះតែងទទួលសេចក្ដីទុក្ខទាំងឡាយព្រោះតែការប្រាថ្នា កាម ។

អាទីបិតា តិណុក្កា គណ្ហន្តំ ទហន្តិ នេវ មុញ្ចន្តិ
ឧក្កោបមា ហិ កាមា ទហន្តិ យេ តេ ន មុញ្ចន្តិ ។

គប់ស្មៅ ដែលភ្លើងកំពុងឆេះតែងឆេះនូវបុគ្គលអ្នកកាន់មិនលែងចេញ ព្រោះថា កាមទាំងឡាយ ប្រៀបដូចជាគប់ភ្លើងតែងឆេះនូវពួកសត្វ ដែលមិនលែងចេញ ។

មា អប្បកស្ស ហេតុ កាម សុខស្ស វិបុលំ ជហិ សុខំ
មា បុថុលោមោវ ពលិសំ គិឡិត្វា បច្ឆា វិហញ្ញសិ ។

សូមទ្រង់កុំលះបង់ នូវសេចក្ដីសុខដ៏ធំទូលាយ ព្រោះហេតុតែសុខក្នុងកាមបន្តិចបន្តួចឡើយ សូមទ្រង់កុំក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយ ដូចជាត្រីលេបនូវសន្ទូច ។

កាមេហិ មា បរិព្ពមសិ សុនខោវ សង្ខលាពទ្ធោ
កាហន្តិ ខុ តំ កាមា ឆាតា សុនខំវចណ្ឌាលា ។

សូមទ្រង់កុំប្រាស់ប្រាល់ ព្រោះតែកាមទាំងឡាយ ដូចសុនខ ដែលគេចងភ្ជាប់នឹង បង្គោល ឪសត្វទាំងឡាយ ជាអ្នកស្រេកឃ្លាន តែងធ្វើតាមសេចក្តីប្រាថ្នា ដូចជាពួកចណ្ឌាល (ព្រានបណ្តើរឆ្កែ ដល់នូវសេចក្តីវិនាស ព្រោះបាន ) នូវឆ្កែ ។

អបរិមិតញ្ច ទុក្ខំ     ពហូនិ ច ចិត្តទោមនស្សានិ

អនុភោហិសិ កាមយុត្តោ បជិនិស្សជ្ជ អទ្ធុវេ កាមេ ។

បើទ្រង់ប្រកបខ្លួនក្នុងកាមនឹងរងទុក្ខ មិនមានប្រមាណ ផង រងទោមនស្សក្នុងចិត្តដ៏ច្រើនផង សូមទ្រង់លះបង់កាមទាំងឡាយជារបស់មិនទៀងចេញ ។

អជរម្ហិ វិជ្ជមានេ     កឹ តវ កាមេហិ យេសុ ជរា

មរណព្យាធិគហិតា       សព្វា សព្វត្ថ ជាតិយោ ។

កាលបើព្រះនិព្វាន ជាធម្មជាតិ មិនចេះចាស់ មានទ្រង់មានប្រយោជន៍ អ្វី ដោយកាមទាំងឡាយ ជារបស់ចចាស់ កំណើតទាំងអស់ក្នុងភពទាំងពួង (សុទ្ធតែ) ត្រូវមរណៈនិងព្យាធិរឹបជាន់ ។

ឥទមជរមិទមមរណំ ឥទមជរាមរណមិទមសោកំ
អសបត្តមសម្ពាធំ អខលិតមភយំ និរុបតាបំ ។

ព្រះនិព្វាននេហ មិនចាស់ ព្រះនិព្វាននេះមិនស្លាប់ ព្រះនិព្វាននេះ ជាបទដែលមិនចាស់ មិនស្លាប់ មិនមានសោកមិនមានសត្រូវ មិនចង្អៀត មិនភ្លាំងភ្លាត់ មិនមានភ័យ មិនក្តៅពោលរាល ។

អធិគតមិទម ពហូហិ អមតំ អជ្ជាបិ ច លភនីយំ ឥទំ
យោ យោនិសោ បយុញ្ជតិ ន ច សក្កា អយដមានេន ។

អមតនិព្វាននេហ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមច្រើនរូបបានហើយ មិនតែប៉ុណ្ណោះទេ ព្រះនិព្វាននេះ គេគប្បីបានក្នុងកាលសព្វថ្ងៃនេះ បុគ្គលណាព្យាយាម ដោយឧបាយប្រាជ្ញា (បុគ្គលនោះ រមែងបាននូវព្រះនិព្វានឡើយ ។

នាងសុមេធា មិនបាននូវសេចក្តីត្រេកអរ ក្នុងសង្ខារ បានពោលហើយ យ៉ាងនេះឯង នាងសុមេធា កាលពន្យល់ស្តេចអនិករត្តៈហើយ ក៏បោះសក់ទាំងឡាយចោលលើផែនដី ។ ស្តេចអនិករត្តៈនោះក្រោកឡើង ផ្គងអញ្ជលីអង្វរ បិតារបស់នាងសុមេធានោះថា សូមព្រះអង្គអនុញ្ញាត បើកឱកាសដល់ព្រះរាជបុត្រីឈ្មោះ

នាងសុមេធា ឲ្យបួសចុះ ដើម្បីឲ្យនាងឃើញនូវព្រះនិព្វាន ដែលគុណដ៏ទៀងទាត់ ។

នាងសុមេធានោះ ដែលជាស្ត្រីតក់ស្លុតចំពោះសោក និង ភ័យ លុះមាតាបិតាបើកឱកាសឲ្យ ក៏បួស ហើយសិក្សានូវអគ្គផលបានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ ។ ព្រះនិព្វាន នោះ ជាគុណដ៏អាស្ចារ្យ ចម្លែក បានកើតមានដល់រាជកញ្ញា លុះក្នុងកាលជាទីបំផុត (ទៀបនឹងបរិនិព្វាន ) នាងបានសម្តែងនូវបុព្វេនិវាសចរិតថា ។

ភគវតិ កោនាគមនេ សង្ឃារាមម្ហិ នវនិវេសម្ហិ

សខិយោ តិស្សោ ជនិយោ វិហារទានំ អទាសិម្ហា ។

កាលព្រះមានព្រះភាគ ទ្រង់ព្រះនាមកោនាគមន: (ត្រាស់ឡើងក្នុងលោក ) យើងជាសម្លាញ់ នឹងគ្នា ទាំងបីនាក់ (គឺនាងធនញ្ជនី ១ នាងខេមា ១ ខ្ញុំ១ ) បានថ្វាយវិហារទានក្នុងអារាមនៃសង្ឃ ជានិវេសន៍ដ៏ថ្មី ។

ទសក្ខត្តុំ ទសសតក្ខត្តុំ សតានិ ច សតក្ខត្តុំ

ទេវេសុ ឧបបជ្ជិម្ហា កោ បន វាទោ មានុសកេសុ ។

(ដោយអានិសង្សនៃវិហារទាននេះ ) យើងទាំងឡាយ បានទៅកើតក្នុងពួកទេវតា ១០ដង ១០០ដង ១០០០ ដង ១០០០០ ដងនឹងចាំបាច់និយាយទៅថ្វីក្នុងពួកមនុស្ស ។

ទេវសុ មហិទ្ធិកា អហុម្ហា មានុសកម្ហិ កោ បន វាទោ

សត្តរតនស្ស មហេសី ឥត្ថីរតនំ អហំ អាសឹ ។

យើងជាអ្នកមានឫទ្ធិច្រើនក្នុងពួកទេវតា នឹងចាំបាច់និយាយ ។ ទៅថ្វីក្នុងពួកមនុស្ស ខ្ញុំបានកើតជាស្ត្រីកែវ ជាអគ្គមហេសីនៃស្តេចដែលមានរតនៈទាំង៧ប្រការ ។

សោ ហេតុ សោ បភវោ តំ មូលំ ច សាសនេ ខមំ

តំ បឋមសមោធានំ តំ ធម្មរតាយ និព្វានំ ។

អានិសង្សនៃវិហារទាននោះ ជាហេតុអានិសង្សនោះ ជាប្រភព (ដែនកើត) អំណោយទាននោះជាការជួបជុំមុនដំបូង អំណោយទាននោះ ជាហេតុឲ្យរលត់កិលេស (ព្រះនិព្វាន) របស់ខ្ញុំដែលជាអ្នកត្រេកអរក្នុងធម៌ ។

ឯវំ កថេន្តិ យេ សទ្ទហន្តិ វចនំ អនោមបញ្ញស្ស

និព្វិន្ទន្តិ ភវគតេ   និព្វិន្ទិត្វា វិជ្ជន្តិតិ ។

ពួកជនណា ជឿនូវព្រះពុទ្ធដីការរបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានប្រាជ្ញា មិនថោកថយ ពួកជននោះ រមែងពោលយ៉ាងនេះថា ពួកជន នឿយណាយក្នុងភព គឺសង្សារវដ្ត លុះនឿយណាយហើយ ក៏ប្រាសចាកតម្រេក ។

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ: ទានកថា

រៀបរៀងដោយ: អគ្គបណ្ឌិត ធម្មាចារ្យ ប៊ុត សាវង្ស

វាយអត្ថបទដោយ: កញ្ញា ជា ម៉ានិត